**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ**....០១....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីដែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋនូវផ្ទៃដី ដែលបានដកហូតដោយដីការបស់សាលាខេត្តក្រចេះកាលពីឆ្នាំ ២០០៦

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ ៖**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០០២ និងចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីចំនួន ២.៨៤៨ ហ.ត (ពីរពាន់ប្រាំបីរយសែសិបប្រាំបីហិកតា) ស្ថិតនៅក្នុងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដែលសាលាខេត្តក្រចេះបានចេញដីកាដកហូតលេខ ៣២ អគខ.ក្រច ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ និងដីកាលេខ ៣០ អគខ.ក្រច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៦ ក្នុងនោះផ្ទៃដីចំនួន ១.២៤២ហ.ត (មួយពាន់ពីររយសែសិបពីរហិកតា) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៧៦ ចន្លោះពីភូមិជើងឃ្លេ ឃុំ២ធ្នូ ស្រុកស្នួល (UTM 661005-1331987) ទៅព្រែកជីមាំង (UTM 664189-1335921) និងចំនួន ១.៦០៦ហ.ត (មួយពាន់ប្រាំមួយរយប្រាំមួយហិកតា) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧៤ ចន្លោះពីភូមិជើងឃ្លូ ស្រុកស្នួល ខេត្តក្រចេះ ទៅដល់ព្រំដែនកម្ពុជា-វៀតណាម (UTM 659307-1332406) ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២ ៖**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈអភិបាលខេត្តក្រចេះ ដើម្បីគ្រប់គ្រង បែងចែក និងប្រើប្រាស់ដី តាមករណីនៃការកាន់កាប់ និងប្រើប្រាស់ដីជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងគម្រោងប្លង់អភិវឌ្ឍន៍តំបន់ព្រំដែនរបស់ខេត្ត ហើយនិងផែនការប្រើប្រាស់ដីធ្លីស្រុកស្នួល។

**មាត្រា ៣ ៖**

ខេត្តត្រូវបង្កើតក្រុមការងារអន្តរស្ថាប័នមួយ ដោយមានជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បី (១)ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មនូវបញ្ជីឈ្មោះអ្នកកាន់កាប់ដីជាក់ស្តែងឡើងវិញឲ្យបានច្បាស់លាស់ (២)ធ្វើបច្ចុប្បន្នកម្មនូវគម្រោងប្លង់អភិវឌ្ឍន៍តំបន់ព្រំដែនរបស់ខេត្តដែលបានសិក្សារៀបចំពីឆ្នាំ១៩៩៦ និងឆ្នាំ២០០០ នោះឡើងវិញ និងត្រូវរៀបចំផែនការប្រើប្រាស់ដីធ្លីស្រុកស្នួលឲ្យបានច្បាស់លាស់ជាមុន លើមូលដ្ឋាននៃនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មុននឹងដំណើរការបែងចែកដីជាក់ស្តែង។

**មាត្រា ៤ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


COORDINATE SYSTEM
Projection: UTM
Zone: 48N
Horizontal Datum: WGS84
Spheroid: WGS84
Unit: Meter
0 1,000 2,000 4,000
Meters